# ទិវាជាតិអំណានលើកទី៨
# ប្រធានបទ "អំណានជាមាគ៌ាឆ្ពោះទៅរកបរិវត្តកម្មវិស័យអប់រំ"

## អត្ថបទប្រឡងប្រណាំងបកស្រាយ
## ប្រធានបទ
## គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល

ស្នេអត្ថបទ ម៉ៅ សំណាង ផលិតករព័ត៌មាន នៃស្ថានីយទូរទស្សន៍ភី.អិន.អិន. ( PNN TV)

### សេចក្តីផ្តើម

ធម្មជាតិបានបង្កើតឱ្យគ្រប់សភាវៈទាំងឡាយដែលមានវត្តមាននៅលើភពផែនដីនេះ សុទ្ធសឹងតែមានគុណតម្លៃផ្សេងៗគ្នា។ មនុស្សក៏ជាសភាវៈមួយក្នុងចំណោមសភាវៈទាំងនោះ ដែលមានគុណតម្លៃដ៏វិសេសជាងគេ ដោយសារតែមនុស្សមានសតិចេះដឹងខុសត្រូវ មានគំនិតច្នៃប្រតិដ្ឋ និងចេះត្រិះរិះពិចារណារឿងរ៉ាវផ្សេងៗនៅក្នុងដំណើរជីវិត។ គុណតម្លៃរបស់មនុស្សបានបង្កើតឱ្យមានការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចនយោបាយ វប្បធម៌ ការអប់រំ មរតកគំនិត និងទ្រឹស្តីពហុវិស័យនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។

គុណតម្លៃមនុស្សបង្កើតឱ្យមានភាពអស្ចារ្យជាច្រើនបន្តពីមួយជំនាន់ទៅមួយជំនាន់សម្រាប់ជាតិសាសន៍នីមួយៗ។ ជាក់ស្តែង បុព្វបុរសខ្មែរបានបង្កើតសមិទ្ធផលជាច្រើនសម្រាប់ប្រជាជាតិខ្មែរ។ នេះជាមរតកគំនិតកើតចេញពីការកសាងគុណតម្លៃផ្ទាល់ខ្លួន និងគុណតម្លៃសម្រាប់សង្គមជាតិ។

គ្រប់គ្នាមើលឃើញដោយផ្ទាល់ភ្នែក ទឹកដី ប្រាង្គប្រាសាទ ចម្លាក់ គំនូរ សិលាចារឹក និងទស្សនៈវិជ្ជាដូនតាខ្មែរ គឺជាមរតកវប្បធម៌ដ៏ផូរផង់សម្រាប់ជាតិសាសន៍ខ្មែរ ព្រមទាំងបង្កើតឱ្យមានទស្សនីយភាពគួរជាទីស្ញប់ស្ញែងដល់គ្រប់ជាតិសាសន៍ដទៃលើពិភពលោក។



រូបភាពតំណាង ប្រាសាទអង្គរវត្ត និងប្រាសាទបាយ័ន ខេត្តសៀមរាប ។

តាមរយៈគុណតម្លៃមនុស្សជាតិដ៏ធំធេងខាងលើនេះ ទើបសង្គមខ្មែរបានឱ្យតម្លៃខ្ពស់ទៅលើគុណតម្លៃរបស់មនុស្សគ្រប់សម័យកាលទាំងអស់។ សង្គមខ្មែរបានចាត់ទុកគុណតម្លៃមនុស្សជាសម្បត្តិដ៏គាប់ប្រសើរសម្រាប់មនុស្សគ្រប់រូប ហើយគុណតម្លៃមួយនេះ អាចបង្កើតបានគ្រប់ពេលវេលានៅក្នុងទិដ្ឋភាពរស់នៅជាក់ស្ដែង ស្របតាមការរីកចម្រើនរបស់សង្គម។ ជាការពិតណាស់ បច្ចុប្បន្នជាយុគសម័យឌីជីថលទំនើបទៅហើយ តើអ្វីជាគុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល?

បញ្ញត្តិ “**គុណតម្លៃមនុស្ស**” និង “**យុគសម័យឌីជីថល**” មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ។ គុណតម្លៃរបស់មនុស្សក្នុងយុគសម័យឌីជីថលជាប្រធានបទដែលគ្របដណ្ដប់ដល់ការប្រព្រឹត្តនិងរបៀបរស់នៅរបស់មនុស្សស្របតាមការរីកចម្រើនសេដ្ឋកិច្ច និងសង្គមជាតិ ។ បញ្ញត្តិ “គុណតម្លៃមនុស្ស” សំដៅលើមនុស្សដែលបង្កើតតម្លៃដល់ខ្លួនឯងស្ដែងឡើងតាមទង្វើកាយ (អាកប្បកិរិយា), វាចា (ពាក្យសម្ដី), និងចិត្ត (អារម្មណ៍)។

ដោយឡែក “យុគសម័យឌីជីថល” ជាបញ្ញត្តិសម្គាល់សម័យកាល ឬដំណាក់កាលរីកច្រើនបច្ចេកវិទ្យាក្នុងរបត់បដិវត្តន៍ឧស្សាហកម្ម ៤.០ ផ្ដោតទៅលើការបង្កើតថ្មី និងគំនិតច្នៃប្រតិដ្ឋ (នវានុវត្តន៍)។ បច្ចេកវិទ្យាទាំងនេះ កំពុងជួយសម្រួលដល់សកម្មភាពរស់នៅរបស់មនុស្ស មានដូចជា បញ្ញាសិប្បនិមិត្ត (AI) និងម៉ាស៊ីនសិក្សាស្វ័យប្រវត្តិ (Machin Learning) ការផ្លាស់ប្ដូរទិន្នន័យដែលអាចបញ្ជាបានដោយស្វ័យប្រវត្តិ (IoT) រ៉ូបូតទិក (robotics) **ប្រព័ន្ធផ្ទុកទិន្នន័យ និងការវិភាគទិន្នន័យឆ្លាតវៃ** (Cloud Computing and Analytics) ជាដើម ។[1]






(រូបភាពតំណាង) របត់បដិវត្តន៍ឧស្សាហកម្ម ៤.០ បច្ចេកវិទ្យាជួយឱ្យមនុស្សផ្ដោតទៅលើការបង្កើតថ្មី និងគំនិតច្នៃប្រតិដ្ឋ (នវានុវត្តន៍)។

[1] IBM, what is Industry 4.0?

តាមរយៈនិយមន័យបញ្ញត្តិទាំងពីរខាងលើនេះ ប្រធានបទ “គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល” រំលេចឱ្យឃើញពីការអភិវឌ្ឍន៍សមត្ថភាពរបស់មនុស្សឱ្យក្លាយជាពលរដ្ឋសកលស្ថិតក្នុងសម័យកាលឌីជីថលកំពុងរីកចម្រើន។ ស្របគ្នានេះដែរ មូលដ្ឋាននៃការកសាងសមត្ថភាពធនធានមនុស្សនៅក្នុងសង្គមកើតចេញការអប់រំផ្នែកសង្គមសាស្ត្រ និងមនុស្សសាស្ត្រ ព្រមទាំងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ស្ថិតនៅក្នុងរបត់បរិវត្តកម្មវិស័យអប់រំ។ ពោលមនុស្សគ្រប់រូបអាចកសាងគុណតម្លៃផ្ទាល់ខ្លួនបាន តាមរយៈនិន្នាការនៃការរីកចម្រើនឌីជីថល និងអក្ខរកម្មឌីជីថល (digital literacy) ។

ត្រង់ចំណុចនេះ អក្ខរកម្មឌីជីថល គឺជាបំណិនដែលចាំបាច់សម្រាប់ការសិក្សា ការរស់នៅ និងការបំពេញការងារនៅក្នុងសង្គមនៃសតវត្សទី២១ ដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដូចជា វេទិកាអ៊ីនធឺណិត បណ្ដាញសង្គម និងឧបករណ៍អេឡិចត្រូនិកចល័ត ។[2]




បំណិនគោលទាំង៥ របស់អក្ខរកម្មឌីជីថល, រូបភាពដោយ SDI(Service Desk Institute), តំណភ្ជាប់រូបភាព ចុចទីនេះ !

គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល គឺជាតម្លៃរបស់បុគ្គលម្នាក់ៗ ដែលផ្ដោតទៅលើរបៀបរស់នៅផ្សារភ្ជាប់ខ្លួននឹងការប្រើប្រាស់ឌីជីថលប្រកបដោយវិជ្ជាជីវៈ, ភាពថ្លៃថ្នូរ, សីលធម៌, ព្រមទាំងសិទ្ធិមនុស្សជាមូលដ្ឋាន ។ គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថលកើតចេញពីការប្រព្រឹត្តរបស់មនុស្សក្នុងសង្គម ។

[2] សៀវភៅ “បដិវត្តកម្មឌីជីថលនៃការអប់រំ”, ទំព័រ១៨, បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, ២០២១

## ១. គុណតម្លៃពិតប្រាកដរបស់មនុស្សក្នុងយុគសម័យឌីជីថល

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំ និងដាក់ចេញផែនការក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល មធ្យមនិងវែង គឺចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០[3]។ ដើម្បីសម្រេចចក្ខុវិស័យនេះ ការអភិវឌ្ឍន៍ឌីជីថលគ្រប់ទម្រង់ជាអាទិភាពសំខាន់បំផុតដែលចូលរួមកសាងមូលធនមនុស្សនៅកម្ពុជា ព្រមទាំងចូលរួមពង្រឹងមូលដ្ឋានគ្រឹះសេដ្ឋកិច្ច និងសុខុមាលភាពសង្គម។

យ៉ាងណាមិញ គុណតម្លៃមនុស្សយុគសម័យឌីជីថល ស្ថិតក្នុងក្របខណ្ឌនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥ ដែលបានរៀបចំឡើងឆ្លើយតបនឹងដំណើរការនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដែលមានសសរស្តម្ភសំខាន់ ៣ គឺពលរដ្ឋឌីជីថល រដ្ឋាភិបាលឌីជីថល និងធុរកិច្ចឌីជីថល[4] ។

គុណតម្លៃពិតប្រាកដរបស់មនុស្សក្នុងយុគសម័យឌីជីថល គឺគុណតម្លៃការអប់រំ (Education) និងគុណតម្លៃសុខុមាលភាពជីវិត (Well-being)។ មនុស្សម្នាក់ៗ អាចបង្កើតគុណតម្លៃពិតប្រាកដសម្រាប់ខ្លួនឯងក្នុងយុគសម័យឌីជីថលតាមរយៈសីលធម៌រស់នៅ មានដូចជា សីលធម៌ផ្ទាល់ខ្លួន សីលធម៌វិជ្ជាជីវៈ និងសីលធម៌សង្គម ។




ការសិក្សាពីរបៀបធ្វើការងារ, ចិត្តវិទ្យាគ្លីនិក, និងសុខភាពសាធារណៈបានរកឃើញថាគុណតម្លៃសុខុមាលភាពជីវិត (Well-being) របស់មនុស្សគ្រប់រូបមានប្រាំពីរចំណុច ។

- សុខភាពផ្លូវចិត្ត (Mental)
- ទំនាក់ទំនង (Relationships)
- បរិស្ថាន (Environmental)
- វប្បធម៌ (Cultural)
- ហិរញ្ញវត្ថុ (Financial)
- សុខភាពរាងកាយ (Physical)
- ការងារ (Occupational)។

មូលដ្ឋានសុខុមាលភាពជីវិត (Well-being) របស់មនុស្សគ្រប់រូបមានប្រាំពីរចំណុច, អានលម្អិតសាកលវិទ្យាល័យ Cornell University ។

---

[3] ឯកសារ "ផែនការក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣", រាជរដ្ឋាភិបាល, ២០១៩

[4] ឯកសារ "គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣០", ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ២០២២

ចំណែកគុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថលទទួលបានពីការអប់រំវិញ គឺផ្ដោតលើចំណេះដឹងពីជំនាញសតវត្សទី២១ ។ ជំនាញសតវត្សទី២១ បែងចែកជា ៣ក្រុមធំៗ រួមមាន ជំនាញនៃការសិក្សារៀនសូត្រ (Learning Skills) ជំនាញផ្នែកអក្ខរកម្ម (Literacy Skills) និងបំណិនជីវិត (Life Skills)។

បំណិនសតវត្សរ៍ទី២១ សំដៅលើបំណិនទន់ និងបំណិនបុរេវិជ្ជាជីវៈ ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងទីផ្សារការងារដែលយុវជនកម្ពុជាត្រូវមាន។ បំណិនសតវត្សទី២១ គឺជាជំនាញដែលជួយពង្រឹង និងអភិវឌ្ឍសមត្ថភាពសិស្សានុសិស្ស ដើម្បីទទួលបានជោគជ័យក្នុងអាជីពការងារ នាសម័យបច្ចេកវិទ្យាទំនើបនេះ[5]។

## បំណិនសតវត្សទី២១ បានបែកជាសមាសភាគ ៣ គឺ៖

### ទី១ - បំណិនសិក្សារៀនសូត្រ (Learning Skills)៖

- ការត្រិះរិះពិចារណា (Critical thinking)
- ការគិតដោយមានភាពច្នៃប្រតិដ្ឋ និងនវានុវត្តន៍ (Creativity)
- ការសហការ (Collaboration)
- ការប្រាស្រ័យទាក់ទង (Communication)។

### ទី២ - បំណិនអក្ខរកម្ម (Literacy Skills)៖

- អក្ខរកម្មព័ត៌មានវិទ្យា (Information literacy)
- អក្ខរកម្មផ្នែកប្រព័ន្ធផ្សព្វផ្សាយ (Media literacy)
- អក្ខរកម្មផ្នែកបច្ចេកវិទ្យា (Technology literacy)។

### ទី៣ - បំណិនជីវិត(Life and Career Skills)៖

- ភាពទន់ភ្លន់និងសម្របសម្រួល (Flexibility)
- ការចេះផ្ដួចផ្ដើមគំនិត (Initiative)
- ភាពជាអ្នកដឹកនាំ (Leadership)
- ផលិតភាពការងារ (Productivity)
- បំណិនសង្គម (Social Skills)។




*រូបភាពក្រាហ្វិកបង្ហាញពីបំណិនសតវត្សទី២១ បែងចែកជាបីសំខាន់ៗសម្រាប់ការសិក្សា និងជាមូលដ្ឋាននៃការអប់រំសតវត្សទី២១។*

[5] សៀវភៅ "បដិវត្តកម្មឌីជីថលនៃការអប់រំ", ទំព័រ១៨, បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, ២០២១

ទន្ទឹមនឹងគុណតម្លៃរបស់មនុស្សកើតចេញពីចំណេះដឹងជំនាញ ឬបំណិនសតវត្សទី២១ ការកសាងគុណតម្លៃផ្ទាល់ខ្លួនសម្រាប់យុវជនកម្ពុជា ជារឿងងាយស្រួលអនុវត្តបំផុត ដែលអាចបង្កើតឡើងតាមរយៈការស្គាល់ខ្លួនឯង, ស្គាល់គោលដៅផ្ទាល់ខ្លួន, ព្រមទាំងមានសីលធម៌ផ្ទាល់ខ្លួនត្រឹមត្រូវ ។




មែកធាងនៃគុណតម្លៃមនុស្សទាំង៨ សម្រាប់ការរស់នៅក្នុងយុគសម័យឌីជីថល ។

គុណតម្លៃរបស់មនុស្សក្នុងយុគសម័យឌីជីថល អាចជួយកសាងគុណភាពជីវិតបុគ្គលបានយ៉ាងច្រើនទាំងការសិក្សា, ការងារ, ទំនាក់ទំនង, និងបង្ហាញពីភាពថ្លៃថ្នូររបស់បុគ្គល។ តាមរយៈគុណតម្លៃដែលបង្កើតឡើងមានឥទ្ធិពលវិជ្ជមានដល់មនុស្សជុំវិញខ្លួន ឬអាចក្លាយជាគំរូភាពសម្រាប់អ្នកដទៃ។

ទីក្រុងមួយមានភាពស្រស់ស្អាតមិនមែនមានអ្នកបោសសំរាមច្រើននាក់តាមដងផ្លូវនោះទេ តែមានប្រជាពលរដ្ឋជាច្រើនយល់ដឹងពីការទុកដាក់សំរាមបានត្រឹមត្រូវ។ ចំណែកគុណតម្លៃមនុស្សនៅក្នុងសង្គមមួយ ក៏មិនមែនរង់ចាំគ្រូមកបង្រៀនគ្រប់ពេលវេលានោះដែរ តែផ្ទុយទៅវិញសង្គមមានប្រជាពលរដ្ឋជាច្រើនព្រមបន្តរៀនដោយវិធីសាស្ត្រផ្សេងៗ ស្របតាមនិន្នាការនៃការរីកចម្រើនឌីជីថលជាសកល។

## ២. សីលធម៌ជួយបង្កើតគុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល

### ក. សីលធម៌ផ្ទាល់ខ្លួន

សង្គមឌីជីថលកាន់តែរីកចម្រើនមនុស្សត្រូវកសាងតម្លៃផ្ទាល់ខ្លួនកាន់តែខ្លាំងតាមរយៈសីលធម៌រស់នៅផ្ទាល់ខ្លួន។ សីលធម៌របស់មនុស្សជាគ្រឿងលម្អបុគ្គលម្នាក់ៗ ដើម្បីបង្កើតវិន័យ សេចក្តីថ្លៃថ្នូរ ចំណេះដឹង ព្រមទាំងសុភមង្គលផ្ទាល់ខ្លួន គ្រួសារ និងសង្គម។ ជាក់ស្តែងការប្រើប្រាស់បណ្តាញសង្គមដែលបង្ហាញពីសីលធម៌ផ្ទាល់ខ្លួន គឺជាគុណតម្លៃពិតប្រាកដសម្រាប់មនុស្សក្នុងយុគសម័យឌីជីថល។




(រូបភាពតំណាង) មធ្យោបាយសិក្សាក្នុងយុគសម័យឌីជីថល ។

សីលធម៌ផ្ទាល់ខ្លួនអាចរៀនបានពីមនុស្សជុំវិញខ្លួន ការអានសៀវភៅ វីដេអូអប់រំ សំឡេងព័ត៌មាន និងតាមរយៈការជួបជុំក្នុងពិធីផ្លូវការអ្វីមួយ។ ការអនុវត្តមេរៀនសីលធម៌ផ្ទាល់ខ្លួន ជាការផ្តល់ឱកាសឱ្យខ្លួនទទួលបានការអប់រំពេញមួយជីវិត។ ការរៀនសូត្រពេញមួយជីវិត (Lifelong Learning) ជារបៀបសិក្សាថ្មីមួយមិនឱ្យខ្លួនឯងជាប់គាំងនឹងកម្រិតចំណេះដឹងដែលមានពីអតីតកាល។

រក្សាទម្លាប់ទទួលយកការរៀនសូត្រពេញមួយជីវិត ជួយឱ្យបុគ្គលមានចំណេះដឹង និងជំនាញកាន់តែច្បាស់លាស់ ហើយបង្កើតបានជាទំនុកចិត្តសម្រាប់ខ្លួនឯង។ បុគ្គលមានចំណេះដឹងទូលំទូលាយ តែងមានទំនុកចិត្តលើការងារដែលខ្លួនកំពុងបំពេញ បើទោះបីកិច្ចការទាំងនោះលំបាកយ៉ាងណាក៏ដោយ ពោលគឺធ្វើដោយទំនុកចិត្តជានិច្ច។

ទំនុកចិត្តដែលកើតចេញពីការសិក្សាពេញមួយជីវិតអាចជួយឱ្យអ្នកដទៃ ឬមនុស្សជុំវិញខ្លួនទទួលយកផ្លែផ្កាពីគំនិតច្នៃប្រតិដ្ឋថ្មីៗ ព្រមទាំងចូលរួមអភិវឌ្ឍន៍សង្គមជាឱ្យរីកចម្រើនកាន់តែលឿនរហ័ស។

## ខ. សីលធម៌វិជ្ជាជីវៈ

ក្រមសីលធម៌និងវិជ្ជាជីវៈ សំដៅដល់ឥរិយាបថប្រព្រឹត្តនៅក្នុងមុខរបរចិញ្ចឹមជីវិតរបស់មនុស្សគ្រប់រូបដោយភាពត្រឹមត្រូវ សេចក្តីថ្លៃថ្នូរ និងគំរូភាពនៅក្នុងសង្គម។ សង្គមកាន់តែរីកចម្រើន បច្ចេកវិទ្យាឌីជីថលកាន់តែទំនើប ក្រមសីលធម៌វិជ្ជាជីវៈកាន់តែសំខាន់សម្រាប់មនុស្ស។

ជាក់ស្តែង ការផ្សព្វផ្សាយព័ត៌មានក្នុងយុគសម័យឌីជីថលអ្នកសារព័ត៌មានត្រូវប្រកាន់ខ្ជាប់ក្រមសីលធម៌និងវិជ្ជាជីវៈសារព័ត៌មាន, គ្រូបង្រៀនចាំបាច់ ត្រូវគោរពក្រមសីលធម៌ និងវិជ្ជាជីវៈគ្រូបង្រៀន, ចំណែកគ្រូពេទ្យត្រូវគោរពក្រមសីលធម៌ និងវិជ្ជាជីវៈគ្រូពេទ្យ។ សីលធម៌អាជីព ឬក្រមសីលធម៌និងវិជ្ជាជីវៈគឺជាម៉ែត្រវាស់គុណតម្លៃរបស់មនុស្សសម័យឌីជីថល។





រូបភាពតំណាង ស្តីពីក្រមសីលធម៌វិជ្ជាជីវៈផ្ទាល់ខ្លួននៅក្នុងអាជីព ។

## គ. សីលធម៌សង្គម

សីលធម៌សង្គមរបស់បុគ្គលជាឥរិយាបថរស់នៅកើតចេញពីសីលធម៌ផ្ទាល់ខ្លួន និងសីលធម៌វិជ្ជាជីវៈផ្ទាល់ខ្លួន។ សីលធម៌សង្គមផ្តោតលើទំនាក់ទំនង របៀបនិយាយស្តី ការចែករំលែក និងសុជីវធម៌រស់នៅដែលបង្ហាញពីចំណេះដឹង និងទេពកោសល្យរបស់បុគ្គល។

ប្រសិនបើបុគ្គលណាម្នាក់ប្រើប្រាស់បណ្តាញសង្គម ហើយបង្កើតមាតិកាមួយដោយប្រើពាក្យពេចន៍ហាក់ពុំមានសីលធម៌ សាធារណជននឹងកំណត់តម្លៃរបស់បុគ្គលម្នាក់នោះ ឬគេអាចដឹងច្បាស់ពីកម្រិតវប្បធម៌ទូទៅរបស់បុគ្គលបានដោយងាយ។ សីលធម៌សង្គមរបស់បុគ្គល ជួយកសាងគុណតម្លៃរបស់មនុស្សនៅ

គ្រប់កាលៈទេសៈ និងជាមូលធនមនុស្សដ៏សំខាន់សម្រាប់សង្គមជាតិ។ ថ្វីត្បិតសតវត្សទី២១ បច្ចេកវិទ្យារីកចម្រើន ប៉ុន្តែនៅគ្រប់កន្លែងការងារតែងត្រូវការមនុស្សមានសីលធម៌ និងជំនាញពិតប្រាកដ។

ជុំវិញការលើកឡើងពីឥទ្ធិពលសីលធម៌សង្គមនេះ នៅក្នុងពិធីជួបសំណេះសំណាលជាមួយប្រតិភូកីឡាអាស៊ានប៉ារ៉ាហ្គេម មុននឹងកីឡាករចេញទៅប្រកួតកីឡាពិការអាស៊ាន លើកទី១១ នៅទីក្រុងសូឡូ ប្រទេសឥណ្ឌូនេស៊ី កាលពីព្រឹកថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២ កន្លងទៅ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជា បានស្នើសុំដល់នារីខ្មែរមួយចំនួនដែលនិយមលេងបណ្តាញសង្គម Tik Tok សូមឱ្យប្រើប្រាស់ពាក្យពេចន៍រក្សាគោរពប្រពៃណី និងភាពថ្លៃថ្នូររបស់ខ្មែរ[6] ។

ការលើកឡើងសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា គឺជាការញញ្ញាក់ស្មារតីដល់យុវជនកម្ពុជាឱ្យគិតពីសីលធម៌សង្គមតាមរយៈការប្រើប្រាស់ពាក្យពេចន៍ឱ្យបានសមរម្យ បង្ហាញពីឥរិយាបថផ្ទាល់ខ្លួនទៅកាន់សាធារជន។



រូបភាពតំណាង ៖ របៀបទំនាក់ទំនង និងឥរិយាបថការងារនៅក្នុងសតវត្សទី២១

តាមរយៈការអប់រំសីលធម៌ផ្ទាល់ខ្លួន សីលធម៌វិជ្ជាជីវៈ និងសីលធម៌សង្គម នោះបុគ្គលអាចកសាងគុណតម្លៃផ្ទាល់បានយ៉ាងងាយនៅក្នុងយុគសម័យឌីជីថល ។

ទន្ទឹមគ្នានេះ បច្ចុប្បន្នយុវជនមានឱកាសអភិវឌ្ឍខ្លួនបានច្រើន ទាំងចំណេះ ជំនាញ និងសីលធម៌។ តម្លៃរបស់បុគ្គលក្នុងយុគសម័យឌីជីថល កើតឡើងដោយសារបុគ្គលព្រមអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួនជាប្រចាំតាមរយៈការអាន ការសិក្សា ការរៀបចំផែនការ ការជជែកដេញដោលតស៊ូមតិ ការងារក្រុម និងការគិត

[6] ប្រសាសន៍សម្តេចតេជោ ហ៊ុន សែន, សំណេះសំណាលប្រតិភូកីឡាអាស៊ានប៉ារ៉ាហ្គេម, ទីស្តីការគណៈរដ្ឋមន្ត្រី, ២០២២

បែបស៊ីជម្រៅគ្រប់មធ្យោបាយ។ សង្គមកាន់តែរីកចម្រើន បច្ចេកវិទ្យាកាន់តែទំនើប មធ្យោបាយអភិវឌ្ឍខ្លួនកាន់តែសម្បូរបែប ហើយមានតែការប្រើប្រាស់ទេពកោសល្យប្រកបដោយវិជ្ជាជីវៈប៉ុណ្ណោះ ទើបអាចបង្កើតគុណតម្លៃផ្ទាល់ខ្លួនក្នុងយុគសម័យឌីជីថលបានពិតប្រាកដ។

## ៣. គុណតម្លៃមនុស្សតាមរយៈការប្រើប្រាស់បណ្ដាញសង្គម

បច្ចុប្បន្នមានមាតិកាជាច្រើនបានបង្កើតឡើងដោយអ្នកលេងបណ្ដាញសង្គម ឬអ្នកយកបណ្ដាញសង្គមហ្វេសប៊ុក, យូធូប, អ៊ីនស្តាក្រាម, និង TikTok ជាដើម ជាមធ្យោបាយបង្ហាញគោលបំណង ឬស្វែងរកប្រាក់ចំណូល។ មាតិកាទាំងនោះ ខ្លះជាសារអប់រំផង ខ្លះជាព័ត៌មានផង ខ្លះជាចំណេះដឹងទូទៅផង និងខ្លះទៀតបង្កើតជាការកម្សាន្តសប្បាយផង។

ប្រសិនបើនិយាយពីមាតិកាដែលមានប្រជាប្រិយភាព និងមានអ្នកទស្សនាច្រើន នៅប្រទេសកម្ពុជាទំនងភាគច្រើនជាមាតិកាវីដេអូបែបកំប្លែងៗ វីដេអូស្តីពីម្ហូបអាហារប្លែកៗ ដែលអាចទៅរួចគ្រប់រឿង រឿងរ៉ាវវាយប្រហារពាក្យសម្ដីដាក់គ្នាជាលក្ខណៈបុគ្គល ឬរឿងរ៉ាវគ្រួសារ និងមាតិកា ឬវីដេអូបែបលេងសើចលេចលើខេីចក្រោមជាដើម។ ប៉ុន្តែក៏មានមាតិកាអប់រំល្អៗជាច្រើនបានបង្កើតឡើងទន្ទឹមគ្នាដែរ។

អ្វីៗទាំងនេះកើតឡើងដោយសារចំណង់ចំណូលចិត្តរបស់អ្នកបង្កើតមាតិកា ទេពកោសល្យរបស់អ្នកបង្កើតមាតិកា កើតពីការត្រាប់តាមអ្នកដទៃ និងអាចកើតឡើងមកពីបំណងស្វែងរកប្រាក់កាស ឬការធ្វើពាណិជ្ជកម្មតាមអនឡាញ។ របៀបរកលុយតាមវីដេអូអនឡាញ ហាក់កំពុងបំផ្លាញការអប់រំសីលធម៌រស់នៅមនុស្សក្នុងសង្គមកម្ពុជា ខណៈអ្នកប្រើប្រាស់បណ្ដាញសង្គមភាគច្រើនពុំទាន់យល់ច្បាស់ពីឌីជីថល។





រូបភាពតំណាង ៖ ការបង្កើតផែនការផលិតមាតិកាលើបណ្ដាញសង្គមត្រឹមត្រូវ (អ្នកបង្កើតមាតិកាផ្លូវការ)

បច្ចុប្បន្នម្ចាស់គណនេយ្យហ្វេសប៊ុកមួយ អាចបង្កើតមាតិកាមួយ ឬច្រើនជាងនេះក្នុងមួយថ្ងៃ ដើម្បីបង្ហាញទៅកាន់មិត្តភក្តិ ឬអ្នកគាំទ្ររបស់ខ្លួន។ មានកត្តាច្រើនណាស់ដែលចូលរួមជំរុញឱ្យមាតិកាបណ្តាញសង្គមកើតឡើងរាយប៉ាយច្រឡំបល់ដល់អ្នកទទួល នោះគឺសីលធម៌អ្នកផលិតកំពុងទាញគុណតម្លៃផ្ទាល់ខ្លួនឱ្យឡើង ឬធ្លាក់ចុះតាមរយៈការបង្ហាញរបស់ខ្លួន។ ខាងក្រោមនេះ ជាហេតុផល ៥ចំណុចដែលមនុស្សងាយបាត់បង់តម្លៃតាមរយៈការប្រើប្រាស់ឌីជីថល។

**ទី១ ការប្រើប្រាស់បណ្តាញសង្គមងាយស្រួល ៖** បណ្តាញសង្គមហ្វេសប៊ុក និង TikTok កំពុងមានប្រជាប្រិយភាព និងប្រើប្រាស់ទូលំទូលាយនៅកម្ពុជា។ បច្ចេកវិទ្យាទំនើប និងឧបករណ៍គាំទ្រសម្បូរបែប មនុស្សគ្រាន់តែមានលទ្ធភាពប្រើទូរស័ព្ទស្មាតហ្វូនថតរូប ថតវីដេអូ ឬក៏អាចបង្កើតមាតិកាមួយបានដោយងាយ។ ថ្វីត្បិតងាយស្រួលបង្កើតមាតិកាក៏ពិតមែន ប៉ុន្តែមិនប្រាកដថា មាតិកានោះមានក្រមសីលធម៌ ឬគោរពដល់តម្លៃអ្នកដទៃឡើយ។ នេះជាហេតុផងធ្វើឱ្យគុណតម្លៃផ្ទាល់ខ្លួនរបស់បុគ្គលធ្លាក់ចុះតាមរយៈការប្រើប្រាស់ឌីជីថល ។




រូបភាពតំណាង ៖ ឧបករណ៍ផលិតមាតិកាបណ្តាញសង្គម

**ទី២ អ្នកបង្កើតមាតិកាមួយចំនួន បង្កើតខ្លឹមសារឡើងចង់បានតែចំនួនអ្នកមើលទស្សនា ៖** អាចសម្គាល់បានថា ពួកគាត់មិនមែនជាអ្នកសារព័ត៌មានអាជីព ដូច្នេះពួកគេពុំបានខ្វល់ ឬគិតថា អ្វីជាវិជ្ជាជីវៈ ឬមិនមែនវិជ្ជាជីវៈនៃការផ្សព្វផ្សាយព័ត៌មានឡើយ។ សំខាន់បំផុតមានអ្នកទស្សនាច្រើន ជាបំណងប្រាថ្នាតែមួយគត់របស់អ្នកផលិតមាតិកាម្នាក់ៗចង់បាន។ ឥទ្ធិពលនេះ ក៏អាចទាញទម្លាក់សីលធម៌អ្នកផលិតមាតិកា ព្រមទាំងធ្វើឱ្យអ្នកទទួលបាត់បង់សីលធម៌ទៅតាមនោះដែរ។

**ទី៣ មាតិកាគ្មានការត្រួតពិនិត្យ ៖** គ្មានការត្រួតពិនិត្យលើមាតិកាជាមុន មានន័យថា ព័ត៌មាន ឬ មាតិកាទាំងឡាយអាចគ្មានការនិពន្ធត្រួតពិនិត្យខ្លឹមសារ។ អ្នកផលិតមិនបារម្ភពីកំហុសការប្រើប្រាស់ពាក្យពេចន៍ មិនគិតដល់ក្បួនខ្នាតឃ្លាល្បះភាសាជាតិឱ្យបានត្រឹមត្រូវ និងមិនបានគិតអំពីសីលធម៌សង្គម ។ ត្រង់នេះ មនុស្សហាក់មិនខ្វល់ពីផលប៉ះពាល់រយៈពេលវែងចំពោះកុមារ យុវជន និងសង្គមឡើយ។

**ទី៤ ការលួចចម្លងគំនិត ៖** ការលួចចម្លងគំនិតផលិត និងចម្លងរបៀបបង្ហាញពីស្នាដៃពីអ្នកដទៃ ឬ មាតិកាបកប្រែមួយចំនួនគ្មានស្នើសុំពីកម្មសិទ្ធិដើម ក៏កំពុងទាញទម្លាក់គុណតម្លៃមនុស្ស។ នេះក៏ជាឱកាសដែលមាតិកាជាច្រើនបានកើតឡើងនៅក្នុងយុគឌីជីថលរីកចម្រើន។ ការគោរពដល់កម្មសិទ្ធិបញ្ញា និងសិទ្ធិម្ចាស់ដើម ជួយឱ្យអ្នកផលិតមាតិកាមានតម្លៃសមជាបញ្ញវន្តសតវត្សទី២១។

**ទី៥ ការចំណាយពេលវេលាគ្មានគោលដៅលើបណ្តាញសង្គម ៖** និន្នាការអ្នកទស្សនាតែងចូលចិត្តគាំទ្រខ្លាំងលើមាតិកាកម្សាន្តសប្បាយៗច្រើនជាងមាតិកាអប់រំ ពិសេសអ្នកដែលចំណាយពេលវេលាច្រើនលើបណ្តាញសង្គមគ្មានគោលដៅ។ កាលណាបុគ្គលម្នាក់ចំណាយពេលតិច តែទទួលបានចំណេះដឹង និងព័ត៌មានត្រឹមត្រូវពីបណ្តាញសង្គម នោះជាផ្នែកមួយដែលអាចជួយពង្រឹងគុណភាពចំណេះដឹងជីវិត។

គួរកត់សម្គាល់ថា លេងបណ្តាញសង្គម និងប្រើប្រាស់បណ្តាញសង្គមមានរូបភាពផ្ទុយគ្នាស្រឡះ។ លេងបណ្តាញសង្គមអាចរុញច្រានមនុស្សឱ្យញៀននឹងបណ្តាញសង្គម ឬអាចលង់ខ្លួនលើបណ្តាញសង្គមដោយងាយបំផុត។ ចំណែកការប្រើប្រាស់បណ្តាញសង្គម គឺកម្រិតពេលវេលាជាក់លាក់លើបណ្តាញសង្គមក្នុងន័យទាញយកផលប្រយោជន៍ពីបណ្តាញសង្គម។ សកម្មភាពកម្សាន្តជ្រុលជាមួយបណ្តាញសង្គមអាចសម្គាល់ ដូចជា ចំណាយពេលវេលាច្រើនលើបណ្តាញសង្គម ព្រមទាំងបង្កើតមាតិកាជាច្រើនតាមអារម្មណ៍ដោយគ្មានមូលដ្ឋានជាក់លាក់។

សរុបជារួមមក ការបង្កើតមាតិកានានាដាក់នៅក្នុងបណ្តាញសង្គម អាចឆ្លុះបញ្ចាំងពីកម្រិតវប្បធម៌ ការអប់រំ និងចំណេះដឹងរបស់អ្នកផលិត។ ការបង្កើតមាតិកាបណ្តាញសង្គមដែលប្រាសចាកពីខ្លឹមសារអប់រំ មិនផ្តល់ចំណេះដឹង និងមិនបានគិតដល់សីលធម៌សង្គមកាន់តែច្រើន កាន់តែបង្ហាញពីចរិកអសីលធម៌ និងកម្រិតគុណតម្លៃបុគ្គលជាអ្នកផលិត។ តាមរយៈហេតុផលទាំង ៥ចំណុចលើកឡើងនេះ អាចសន្និដ្ឋានបានថា គុណតម្លៃរបស់មនុស្សនៅក្នុងយុគសម័យឌីជីថល មួយផ្នែកក៏កើតពីការប្រើប្រាស់ឌីជីថលផងដែរ។ គុណតម្លៃមនុស្សនៅក្នុងយុគសម័យឌីជីថល គិតទាំងការប្រើប្រាស់បណ្តាញសង្គមរបស់បុគ្គល។

## ៤. សេចក្តីសន្និដ្ឋាន

តាមរយៈការបកស្រាយអំពីប្រធានបទ “គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល” អាចរកឃើញហេតុផលជាក់លាក់មួយចំនួន ដែលជាមូលដ្ឋានជួយកសាងគុណភាពជីវិតបុគ្គលទាំងការសិក្សា, ការងារ, ទំនាក់ទំនង, និងបង្កើតភាពថ្លៃថ្នូរសម្រាប់បុគ្គល។ គុណតម្លៃដែលមនុស្សបង្កើតឡើងមានឥទ្ធិពលមានដល់មនុស្សជុំវិញខ្លួន ឬអាចក្លាយជាគំរូភាពសម្រាប់អ្នកដទៃ។

គុណតម្លៃរបស់មនុស្សកើតចេញពីចំណេះដឹង ជំនាញ ឬបំណិនសតវត្សទី២១ ។ ជាមួយគ្នានេះ ការកសាងគុណតម្លៃផ្ទាល់ខ្លួនសម្រាប់យុវជនកម្ពុជាគ្រប់រូប  គឺជាភារៈសំខាន់បំផុតសម្រាប់ការរស់នៅក្នុងសង្គមឌីជីថលកំពុងរីកច្រើន ដូចជា ការស្គាល់ខ្លួនឯង, ឱ្យតម្លៃដល់ការអប់រំជាអាទិភាព, ស្គាល់គោលដៅផ្ទាល់ខ្លួន, ព្រមទាំងប្រតិបត្តិសីលធម៌ផ្ទាល់ខ្លួនបានត្រឹមត្រូវ សមតម្លៃជាយុវជនខ្មែរមានវប្បធម៌ដ៏រុងរឿង៕

ឯកសារយោង


១. វចនានុក្រមខ្មែរ សម្ដេចសង្ឃរាជ ជួន ណាត, ពុទ្ធសាសនបណ្ឌិត្យ
២. សៀវភៅ "បដិវត្តកម្មឌីជីថលនៃការអប់រំ", បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, ២០២១
៣. ផែនការក្របខ័ណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣, រាជរដ្ឋាភិបាល, ២០១៩
៤. គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣០, ក្រសួងប្រៃសនីយ៍និងទូរគមនាគមន៍, ២០២២
៥. គេហទំព័រ Applied Educational Systems តំណភ្ជាប់ [ចុចទីនេះ]
៦. គេហទំព័រសាកលវិទ្យាល័យ CORNELL UNIBERSITY តំណភ្ជាប់ [ចុចទីនេះ]